មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## រាជធានីភ្នំពេញ៖ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជារៀបចំកិច្ចពិភាក្សាតុមូលស្តីពីដីធ្លី និងសិទ្ធិរបស់ជនជាតិដើមភាគតិច នៅសណ្ឋាគារ ហ៊ែរ ប៊ុន្នី ទីរួមខេត្តក្រចេះ

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (**ម.ស.ម.ក**) នឹងរៀបចំកិច្ច ពិភាក្សាតុមូលស្តីអំពី **"ដីធ្លី និងសិទ្ធិរបស់ជនជាតិដើមភាគតិច"** ដែលចូលរួមដោយតំណាងក្រុមជនជាតិដើម ភាគតិចដែលរងផលប៉ះពាល់ក្នុងជម្លោះដីធ្លី តំណាងមកពីស្ថាប័នពាក់ព័ន្ធ តំណាងអង្គការមិនមែនរដ្ឋាភិបាលនានា និងតំណាងរាស្ត្រមកពីគណបក្សនានា ដែលមានចំនួនសរុបប្រមាណ ៣០នាក់។

កិច្ចពិភាក្សាតុមូលនេះនឹងរៀបចំឡើងនៅសណ្ឋាគារ ***ហ៊ែរ ប៊ុន្នី*** ស្ថិតនៅផ្លូវជាតិលេខ ៧E ទល់មុខកងរាជអាវុធហត្ថទីរួមខេត្តក្រចេះ ។ គោលបំណងក្នុងការរៀបចំកិច្ចពិភាក្សានេះឡើងគឺដើម្បីផ្តល់ឱកាស ដល់ក្រុមដែលទទួលផលប៉ះពាល់ដោយសារវិវាទដីធ្លីនៅកម្ពុជា អង្គការសង្គមស៊ីវិល គណបក្សនយោបាយ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត បានពិភាក្សាស្វែងយល់អំពីស្ថានភាពជាក់ស្តែងនៃវិវាទដីធ្លីដែលបានកើតមានឡើង តាមរូបភាពស្របច្បាប់ និងមិនស្របច្បាប់បណ្តាលឲ្យមានភាពស្មុគស្មាញពិបាកដោះស្រាយ និងពុំធានាបាននូវសុវត្ថិភាពពិតប្រាកដ ចំពោះសិទ្ធិមានដីធ្លីរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងសិទ្ធិមានដីធ្លីរបស់ជនជាតិដើមភាគ-តិច អនុលោមទៅតាមច្បាប់ជាតិ និងអន្តរជាតិជាធរមាន។

ក្នុងកម្មវិធីពេលព្រឹកនៃកិច្ចពិភាក្សាតុមូលនេះ អ្នកចូលរួមដែលមាន សមាសភាពជាតំណាងក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ក្នុងជម្លោះដីធ្លី តំណាងមកពីស្ថាប័នពាក់ព័ន្ធ និងតំណាងអង្គការសង្គមស៊ីវិល ធ្វើការសន្ទនា និងពិភាក្សាអំពីបញ្ហាដែលបានលើកឡើងខាងលើ ព្រមទាំងការផ្តល់ជាអនុសាសន៍ក្នុងការធានាដល់សិទ្ធិមានដីធ្លីរបស់ជនជាតិដើមភាគតិច អនុលោមទៅតាមច្បាប់ជាធរមាន។

រាល់បញ្ហា ការព្រួយបារម្ភ និងអនុសាសន៍នានាដែលបានលើកឡើងដោយក្រុមអ្នកចូលរួមក្នុងកម្មវិធីពេលព្រឹកនៃកិច្ចពិភាក្សានេះ នឹងត្រូវលើកបង្ហាញជូនដល់តំណាងរាស្ត្រពីគណបក្សនយោបាយនានា ដែលអញ្ជើញចូលរួមក្នុងកម្មវិធីនាពេលរសៀលនៃកិច្ចពិភាក្សាតុមូលនេះ ដោយរួមមានទាំងការឆ្លើយតបរបស់តំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗ ចំពោះបញ្ហា និងការព្រួយបារម្ភ ដែលបានលើកឡើងដោយអ្នកចូលរួម ព្រមទាំងមានការពិចារណាក្នុងការដាក់បញ្ចូលនូវអនុសាសន៍របស់អ្នកចូលរួមទៅក្នុងគោលនយោបាយដីធ្លី របស់ពួកគេសម្រាប់ការប្រកួតប្រជែងបោះឆ្នោតសភាជាតិអាណត្តិទី ៥ ក្នុងឆ្នាំ២០១៣ ខាងមុខនេះ។

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

លោក វណ្ណ សូផាត មន្ត្រីសម្របសម្រួលកម្មវិធីកំណែទម្រង់ដីធ្លីនៃ (**ម.ស.ម.ក**)
ទូរស័ព្ទលេខ +៨៥៥ ១២ ៩៤១ ២០៦
អ៊ីម៉ែល៖ vann.sophath@cchrcambodia.org

#798, St. 99, Sangkat Boeung Trabek, Khan Chamcamorn, Phnom Penh, Cambodia
Tel: (855) 23 726 901/Fax: (855) 23 726 902, e-mail: info@cchrcambodia.org,
website: www.cchrcambodia.org